# សង្កាត់សាលារៀនអូកឡិនដ៍
## ក្រុមប្រឹក្សាភិបាល
## សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

## ស្តីអំពីការមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនគ្រប់គ្រាន់
## សម្រាប់ឆ្នាំសិក្សា 2023-2024

**ជូនចំពោះភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស គឺមាតាបិតា លោកគ្រូ-អ្នកគ្រូ មេដឹកនាំនៃអង្គភាពខាងចរចារ និងសមាជិកនៃសហគមន៍ ដែលមានចំណាប់អារម្មណ៍ទៅលើការងារនានានៃសង្កាត់សាលារៀនអូកឡិនដ៍។**

**សូមកត់សំគាល់ថា នៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2023** នៅក្នុងកិច្ចប្រជុំធម្មតានៃក្រុមប្រឹក្សាភិបាល (“ក្រុមប្រឹក្សា”) នៃសង្កាត់សាលារៀនអូកឡិនដ៍ ក្រុមប្រឹក្សានឹងបើកអង្គប្រជុំជាសាធារណៈមួយស្តីអំពីការមានសៀវភៅសិក្សា និងសម្ភារៈបង្រៀន[1] គ្រប់គ្រាន់ នៅវេលាម៉ោង 7 យប់ ឬបើកយ៉ាងឆាប់បន្ទាប់ពីពេលវេលាហ្នឹង — សំរាប់ឆ្នាំសិក្សា 2023-2024 តាមរយៈអ៊ិនធឺណិត (តាមកម្មវិធី Zoom និង Granicus Live Manager ក្នុងពេលដំណាលគ្នា)។ បន្ទាប់ពីការបញ្ចប់សវនការមក ក្រុមប្រឹក្សាភិបាលត្រូវធ្វើការកំណត់តាមសេចក្តីសម្រេចដូចមានចុះជូននៅក្នុងប្រការ (ក), (ខ) និង (គ) ខាងក្រោមនេះ។

ផ្នែកទី 60119 នៃក្រមអប់រំកាលីហ្វ័រនីញ៉ា តម្រូវអោយក្រុមប្រឹក្សាភិបាលបើកសវនាការជាសាធារណៈមួយ ក្នុងរយៈពេលសាលាបើកឱ្យសិស្សចូលរៀនបានប្រាំបីសប្តាហ៍ដំបូង ដើម្បីធ្វើការកំណត់៖

(ក) ថាតើសិស្សម្នាក់ៗ នៅក្នុងសាលារៀននីមួយៗរបស់សង្កាត់ មានសៀវភៅសិក្សា ឬមានសម្ភារៈបង្រៀនគ្រប់គ្រាន់ ឬមានទាំងពីរ ដែលស្របតាមស្តង់ដារមាតិកាសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សា [អប់រំ] ថ្នាក់រដ្ឋ នៅក្នុងមុខវិជ្ជានីមួយៗដូចតទៅនេះ តាមដែលសមស្របដែលត្រូវនឹងមាតិកាសិក្សា និងខួបរបស់គំរោងនៃកម្មវិធីសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៃរដ្ឋកាលីហ្វញ៉ា៖

- គណិតវិទ្យា,
- វិទ្យាសាស្ត្រ,
- ប្រវត្តិវិទ្យា-សង្គមវិទ្យា,
- សិល្បៈភាសាអង់គ្លេស រួមទាំងសមាសភាគអភិវឌ្ឍន៍ភាសាអង់គ្លេសនៃកម្មវិធីដែលបានអនុម័ត; និង

(ខ) ថាតើសិស្សម្នាក់ៗដែលបានចុះឈ្មោះចូលរៀនថ្នាក់ភាសាពិភពលោក ឬថ្នាក់សុខភាព មានសៀវភៅសិក្សា ឬមានសម្ភារៈបង្រៀនគ្រប់គ្រាន់ ដែលស្របតាមស្តង់ដារនៃមាតិកាសិក្សា និងខួបរបស់គំរោងនៃកម្មវិធីសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលថ្នាក់រដ្ឋសម្រាប់មុខវិជ្ជាទាំងនោះ; និង

(គ) ការមានប្រដាប់ប្រដារគ្រប់គ្រាន់សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត ដែលជាប់ទាក់ទងទៅនឹងថ្នាក់អនុវត្តវិទ្យាសាស្ត្រ ដែលបានផ្តល់អោយសិស្សទាំងអស់ដែលរៀនថ្នាក់ទី 9 ដល់ទី 12។

សេចក្តីសម្រេច និងរបាយការណ៍ (តាមការរកឃើញនានា) ដែលបានដាក់ស្នើសុំមួយច្បាប់ ស្តីអំពីការមានសៀវសិក្សា និងសម្ភារៈបង្រៀនគ្រប់គ្រាន់ នៃឆ្នាំសិក្សា 2023-2024 របស់សង្កាត់ គឺមានដាក់ជូន ដើម្បីធ្វើការពិនិត្យមើលតាមរយៈវើលវ៉ាយវិប (World Wide Web) នៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2023 នៅគេហទំព័រ៖ http://www.ousd.org/domain/69។

s/Kyla Johnson Trammell
លេខាធិការនៃក្រុមប្រឹក្សាភិបាល
សង្កាត់សាលារៀនអូកឡិនដ៍

[1] ការមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនគ្រប់គ្រាន់ មានន័យថា សិស្សម្នាក់ៗ រួមទាំងសិស្សអ្នករៀនអង់គ្លេសដែរ គឺមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនស្របតាមស្តង់ដារ ឬមានទាំងពីរ ដើម្បីប្រើប្រាស់នៅក្នុងថ្នាក់រៀន និងយកទៅផ្ទះ។ [វា] អត់តម្រូវឱ្យមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនពីរឈុត ឬមានទាំងពីរប្រភេទ ដើម្បីប្រើប្រាស់នៅក្នុងថ្នាក់រៀន ឬនៅឯផ្ទះទេ។ ក្រមអប់រំផ្នែកទី 60119(c)(1)

| Board Office Use: **Legislative File Info.** | |
|---|---|
| File ID Number | 23-1954 |
| Introduction Date | 9/13/23 |
| Enactment Number | |
| Enactment Date | |

OAKLAND UNIFIED SCHOOL DISTRICT
Community Schools, Thriving Students

# អនុស្សរណៈអមឯកសារនៃក្រុមប្រឹក្សា

*ជូនចំពោះ* ក្រុមប្រឹក្សាអប់រំ

*ពី* Kyla Johnson-Trammell អគ្គនាយកនៃសង្កាត់សាលារៀន
Sondra Aguilera មន្ត្រីជាន់ខ្ពស់គ្រប់គ្រងវិជ្ជាស្ថានអប់រំ
Alicia Arenas នាយកផ្នែកណែនាំសាលាបឋមសិក្សា, នាយកដ្ឋាននៃកម្មវិធីសិក្សា និងណែនាំ

*ថ្ងៃខែឆ្នាំប្រជុំ* 13 កញ្ញា 2023

*ប្រធានបទ* សវនាការជាសាធារណៈ, របាយការណ៍ និងការអនុម័តដោយក្រុមប្រឹក្សាអប់រំ
ដំណោះស្រាយលេខ 2324-0008 - ការមានសៀវភៅសិក្សា និងសម្ភារៈឧបទេសគ្រប់គ្រាន់ - ឆ្នាំសិក្សា 2023-24

---

*សំណើនៃក្រុមប្រឹក្សា* បើកសវនាការជាសាធារណៈ ហើយនិង បន្ទាប់ពីបិទសវនាការមក អនុម័តដំណោះស្រាយលេខ 2324-0008, - ការមានសៀវភៅសិក្សា និងសម្ភារៈឧបទេសគ្រប់គ្រាន់ - សម្រាប់សាលារៀនទាំងអស់ តាមតម្រូវការ ដោយក្រមអប់រំផ្នែកទី 60119 (ករណី Williams)។

*ព្រឹត្តិការណ៍កន្លងមក*

នៅខែឧសភាឆ្នាំ 2000 សហជីព ACLU និងអ្នកតស៊ូមតិផ្សេងៗដើម្បីផលប្រយោជន៍សាធារណៈ ដែលតំណាងឱ្យសិស្សទូទាំងរដ្ឋ បានដាក់ពាក្យបណ្ដឹងប្រឆាំងនឹងរដ្ឋកាលីហ្វ័រញ៉ា, អគ្គនាយកនៃក្រសួងណែនាំសាធារណៈ, ក្រុមប្រឹក្សាអប់រំនៃរដ្ឋ និងក្រសួងសិក្សាធិការនៃរដ្ឋកាលីហ្វ័រញ៉ា។ មូលដ្ឋាននៃបណ្ដឹង គឺអាគារសាលារៀនមានលក្ខណៈសមរម្យ និងប្រកបដោយសុវត្ថិភាព, សម្ភារៈឧបទេស និងគ្រូបង្រៀនដែលមានគុណសម្បត្តិគ្រប់គ្រាន់។

ការិយាល័យអប់រំនៃខោនធី Alameda (ACOE) ធ្វើសវនកម្មប្រចាំឆ្នាំដើម្បីវាយតម្លៃលើភាពមានគ្រប់គ្រាន់នៃសម្ភារៈឧបទេស និងការបិទប្រកាសតាមកាតព្វកិច្ចនៃនីតិវិធីបណ្ដឹងជាសកល (UCPs)។ ឆ្នាំនេះ ACOE បានធ្វើសវនកម្មនៅតាមទីសាលារៀនចំនួន 50 នៅចន្លោះថ្ងៃទី 17 ខែសីហាដល់ថ្ងៃទី 31 ខែសីហា ឆ្នាំ 2023។ លទ្ធផលនៃការស្ទង់មតិរបស់ ACOE រហូតមកដល់បច្ចុប្បន្ននេះ បង្ហាញឱ្យឃើញថា សាលារៀនទាំងអស់មានសៀវភៅសិក្សា និង/ឬ សម្ភារៈឧបទេសគ្រប់គ្រាន់ដែលតម្រូវដោយ SB 550។

ដំណើរការដាក់កម្មង់សម្ភារៈឧបទេសសម្រាប់ឆ្នាំសិក្សា 2023-24 មានដូចខាងក្រោមនេះ៖

1. ការដាក់កម្មង់សម្ភារៈឧបទេស៖ សង្កាត់សាលារៀនអូកឡិនដ៍ (OUSD) បានទិញសម្ភារៈបោះពុម្ព និងសម្ភារៈឌីជីថលសម្រាប់កម្មវិធីសិក្សាស្នូល និងសម្រាប់កម្មវិធីបន្ថែមជាច្រើនទៀតផងដែរ។ កុំព្យូទ័រ Chromebook និង Internet Hotspot ត្រូវបានផ្ដល់ឱ្យដោយសង្កាត់ ដើម្បីគាំទ្រសិស្សក្នុងការចូលប្រើកម្មវិធីសិក្សាស្នូលពីចម្ងាយ។ សម្ភារៈបង្រៀនទាំងអស់ត្រូវបានដាក់កម្មង់តាមការប៉ាន់ប្រមាណទុកជាមុន

លើការចុះឈ្មោះចូលរៀននៅឆ្នាំ 2023-24, ការឆ្លើយតបទៅនឹងការសាកសួរព័ត៌មាននៃផ្នែកបំរើសេវាសៀវភៅសិក្សានៃសាលារៀនដែលបានកំណត់ ហើយនិងនៅក្នុងការសម្របទៅតាមកិច្ចប្រជុំមួយទល់មួយ ជាមួយនឹងបុគ្គលិកផ្នែកសម្ភារៈឧបទេស។។

| *សម្ភារៈដែលដាក់កម្មង់ឱ្យបានមុន* | *កម្មវិធី / សម្ភារៈ* | *បានបញ្ជូនទៅកាន់ទីសាលារៀននានា* |
|---|---|---|
| កក្កដា 2023 | Creative Curriculum Kits | សីហា 2023 |
| កក្កដា 2023 | Eureka Math teacher materials, consumable books | សីហា 2023 |
| កក្កដា 2023 | Systematic Instruction in Phonics, Phonemic Awareness, and Sight Words (SIPPS) | សីហា 2023 |
| កក្កដា 2023 | Learning Without Tears consumables | សីហា 2023 |
| កក្កដា 2023 | EL Education consumable books, trade books, etc. | សីហា 2023 |
| កក្កដា 2023 | Benchmark Adelante Advance | សីហា 2023 |
| កក្កដា 2023 | Illustrative Mathematics consumables (HS) | សីហា 2023 |
| កក្កដា 2023 | Pearson History Books and Digital Materials (MS) | សីហា 2023 |
| កក្កដា 2023 | Next Generation FOSS lab kits, books, digital materials (MS) | សីហា 2023 |
| កក្កដា 2023 | Next Generation FOSS lab kits, books, digital materials (ES) | សីហា 2023 |
| កក្កដា 2023 | Newsela Digital CA Custom Collections | សីហា 2023 |
| កក្កដា 2023 | Collaborative Classroom | សីហា 2023 |
| កក្កដា 2023 | ELD 6-8 for LTELs English 3D HMH | សីហា 2023 |
| កក្កដា 2023 | Vista World Language books and digital materials | សីហា 2023 |
| កក្កដា 2023 | National Geographic Newcomer Books | សីហា 2023 |
| កក្កដា 2023 | Illustrative Mathematics consumables (MS) | សីហា 2023 |
| កក្កដា 2023 | AP Statistics texts and digital materials | សីហា 2023 |
| កក្កដា 2023 | Follett 9th Grade ELA | សីហា 2023 |
| កក្កដា 2023 | Special Education: Spire Reading TK-8 | សីហា 2023 |
| កក្កដា 2023 | Special Education: Unique K-YA | សីហា 2023 |
| កក្កដា 2023 | Special Education: TouchMath TK-2 | សីហា 2023 |
| កក្កដា 2023 | Special Education: TeachTown K-YA | សីហា 2023 |
| កក្កដា 2023 | Special Education: V Math 3-8 | សីហា 2023 |
| កក្កដា 2023 | Special Education: IXL 9-12 | សីហា 2023 |
| កក្កដា 2023 | Replacement purchases for all other Core Curriculum materials | សីហា - កញ្ញា 2023 |

**2.** ការរក្សាទុកកំណត់ត្រា៖ សៀវភៅបញ្ជីត្រូវបានរក្សាទុកសម្រាប់ការកម្មង់នីមួយៗដែលបង្ហាញពីសម្ភារៈ និងបរិមាណនានាដែលបានដាក់កម្មង់។ ឯកសារនីមួយៗត្រូវបានធ្វើបច្ចុប្បន្នភាព បន្ទាប់ពីការបានដាក់កម្មង់។ ឯកសារដែលបានដាក់កម្មង់ គឺអាចដាក់ជូនបានតាមការស្នើសុំ។ លើសពីនេះ ចំពោះគោលបំណងនៃ

ការទទួលខុសត្រូវ និងការរក្សាបញ្ជីសារពើព័ន្ធនៃឃ្លាំងស្តុកទំនិញឱ្យមានលក្ខណៈត្រឹមត្រូវ និងទាន់សម័យ, ការស្នើសុំសម្ភារៈឧបទេសនៃសាលានីមួយៗ គឺមានតម្កល់ទុកនៅក្នុងសំណុំឯកសារ។ នេះរាប់បញ្ចូលទាំងព័ត៌មាន រាល់ពេលណាដែលសាលារៀននានា ចូលមកទទួលយកសម្ភារៈពីឃ្លាំងផងដែរ។

3. កិច្ចប្រជុំថ្នាក់ដឹកនាំសាលារៀន៖ បុគ្គលិកនៃសង្កាត់បានឆ្លើយឆ្លងគ្នាជាមួយបុគ្គលិកសាលាតាមរយៈអ៊ីម៉ែល ចាប់ពីខែមីនាដល់ខែកញ្ញា។ គោលបំណងនៃកិច្ចប្រជុំទាំងនេះ គឺដើម្បីពិនិត្យលើចំណុចនានាដូចតទៅនេះ៖

- ពិនិត្យឡើងវិញលើទិន្នន័យចុះឈ្មោះចូលរៀនជាក់ស្តែង និងដែលបានប៉ាន់ប្រមាណទុកជាមុន
- ពិនិត្យឡើងវិញលើភាសាបង្រៀននៅក្នុងកម្មវិធីទ្វេភាសា និងកម្មវិធីបញ្ជ្រាបពីរភាសា
- ពិនិត្យឡើងវិញលើផ្នែកវគ្គសិក្សាថ្មីដែលបានបង្កើត
- ពិនិត្យឡើងវិញលើទិន្នន័យជាក់លាក់នៃសាលារៀន អំពីអ្វីៗដែលបានដាក់កម្ម៉ង់រហូតមកដល់ពេលបច្ចុប្បន្ន

4. ទម្រង់បែបបទស្នើសុំសម្ភារៈឧបទេស៖ ចាប់ផ្តើមពីខែសីហាមក នាយកសាលាបានជូនដំណឹងដល់បុគ្គលិកផ្នែករកគំនិតថ្មីសម្រាប់កម្មវិធីសិក្សា និងបង្រៀន អំពីតម្រូវការសៀវភៅបន្ថែម ដោយផ្អែកលើចំនួនចុះឈ្មោះចូលរៀនបន្ថែម ឬសម្ភារៈដែលបានបាត់បង់ និង/ឬ ខូចខាត។ នាយកសាលាបានដាក់សំណុំបែបបទស្នើសុំសម្ភារៈឧបទេសដែលបានបញ្ជាក់ពីចំនួនសម្ភារៈបន្ថែមដែលត្រូវការ។

5. ការបណ្តុះបណ្តាលតាមរបៀប Williams សម្រាប់នាយកសាលា និងបុគ្គលិក OUSD៖ បុគ្គលិក OUSD បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលតាមរបៀប Williams នៃ OUSD  នៅថ្ងៃទី 25 ខែ 7 ឆ្នាំ 2023 តាមកម្មវិធី Zoom ហើយការិយាល័យអប់រំនៃខោនធីអាឡាមីដា (ACOE) បានបំពេញវគ្គសិក្សាអសមកាលតាមកម្មវិធី Canvas។ វគ្គសិក្សាតាមកម្មវិធី Canvas នេះ បានផ្តល់នូវចំណុចសំខាន់ៗអំពីដំណើរការជម្រះបញ្ជី និងការរំពឹងទុកចំពោះសាលារៀននានា។

6. ការមកជួយភ្លាមៗតាមការហៅ៖ បុគ្គលិកផ្នែកកម្មវិធីសិក្សា និងណែនាំ ព្រមទាំងការិយាល័យបណ្តាញ បានធានាយ៉ាងណាឱ្យនាយកសាលានានា ទទួលបាននូវការជួយទ្រទ្រង់មួយទល់មួយភ្លាមៗតាមរយៈដំណើរការ Williams។

7. សេចក្តីរំលឹកតាមអ៊ីមែល៖ នាយកសាលា នឹងត្រូវបានគេអ៊ីមែលជូននូវសេចក្តីរំលឹកយ៉ាងទៀងទាត់ អំពីថ្ងៃខែផុតកំណត់ និងការធ្វើបច្ចុប្បន្នភាពករណី Williams។

*ផលប៉ះពាល់សារពើពន្ធ*

8. ការត្រួតពិនិត្យបញ្ជីគណនីដូចមែនទែន៖ បុគ្គលិកមកពីនាយកដ្ឋានការិយាល័យកណ្តាលផ្សេងៗ ត្រូវបានបណ្តុះបណ្តាលឱ្យចេះធ្វើការត្រួតពិនិត្យបញ្ជីគណនីដូចមែនទែន ដើម្បីរៀបចំការត្រួតពិនិត្យបញ្ជីគណនី ACOE។ អ្នកធ្វើការត្រួតពិនិត្យបញ្ជីគណនីដូចមែនទែនរបស់ OUSD បានកំណត់ពេលវេលាចុះធ្វើទស្សនកិច្ចតាមទីសាលារៀន ប្រហែលជាមួយសប្តាហ៍មុនការធ្វើការត្រួតពិនិត្យបញ្ជីគណនី ACOE។ ថ្នាក់រៀននានាត្រូវបានធ្វើទស្សនកិច្ច ដើម្បីរកមើលការបិទប្រកាស និងសម្ភារៈឧបទេសដែលបានតម្រូវឡើងដោយច្បាប់។ អ្នកធ្វើការត្រួតពិនិត្យបញ្ជីគណនីដូចមែនទែន ធ្វើការជាមួយបុគ្គលិករបស់សង្កាត់សាលារៀន ដើម្បីដោះស្រាយបញ្ហាណាមួយដែលអាចកើតឡើង រួមទាំងការស្នើសុំសម្ភារៈបន្ថែម។

*អនុសាសន៍*

សម្រាប់ឆ្នាំសារពើពន្ធ 2023-24 ថវិកាការងារសម្រាប់ សៀវភៅសិក្សា / សម្ភារឧបទេស មានដូចខាងក្រោមនេះ៖

| ថវិការ | ថវិការការងារ | ថវិកាបម្រុងទុក<br>គិតត្រឹមថ្ងៃទី 1 កញ្ញា 2023 |
|---|---|---|
| Lottery | $2,960,402.00 | $2,900,895.00 |
| Supplemental and Concentration Carryover | $4,526,849.00 | $4,526,849.00 |

បើកសវនាការជាសាធារណៈ ហើយនិង បន្ទាប់ពីការបិទសវនាការមក អនុម័តដំណោះស្រាយលេខ 2223-0004 – ការមានសៀវភៅសិក្សា និងសម្ភារៈឧបទេសគ្រប់គ្រាន់ – សម្រាប់សាលារៀនទាំងអស់ ដូចបានតម្រូវឡើងដោយច្បាប់អប់រំផ្នែកទី 60199។ (ករណី Williams)។

*ឯកសារភ្ជាប់មកជាមួយ៖*

- ដំណោះស្រាយលេខ 2324-0008
- បទបង្ហាញ - ស្ថានភាពនៃការសៀវភៅសិក្សា និងសម្ភារៈឧបទ្ទេសគ្រប់គ្រាន់

OAKLAND UNIFIED SCHOOL DISTRICT
Community Schools, Thriving Students

# ដំណោះស្រាយ
# នៃ
# ក្រុមប្រឹក្សាភិបាល
# នៃ
# សង្កាត់សាលារៀនអូកឡិនដ៍
# ដំណោះស្រាយលេខ 2324-0008

## ការមានសៀវភៅសិក្សា ឬសម្ភារៈឧបទេសគ្រប់គ្រាន់
## សម្រាប់ឆ្នាំសិក្សា 2023-24
## (ច្បាប់អប់រំផ្នែកទី 60119 និង 5 CCR 9531)

ដោយហេតុថា ក្រុមប្រឹក្សាភិបាលនៃសង្កាត់សាលារៀនអូកឡិនដ៍ ដើម្បីអនុលោមតាមតម្រូវការនានានៃក្រមអប់រំលេខ 60119 បានបើកសវនាការជាសាធារណៈមួយនៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2023 នៅម៉ោង 5:30 ល្ងាច ឬអាចចាប់ផ្តើមភ្លាមៗក្រោយពេលហ្នឹងបន្តិចដើម្បីស្តាប់រឿងរ៉ាវដែលបានធ្វើនៅ ឬមុនរយៈពេលចូលរៀនបានប្រាំបីសប្តាហ៍ (នៅចន្លោះថ្ងៃដំបូងដែលសិស្សចូលរៀន និងសប្តាហ៍ទីប្រាំបី ចាប់ពីថ្ងៃហ្នឹងមក) ហើយដែលមិនបានធ្វើនៅក្នុងអំឡុងពេល ឬធ្វើឡើងភ្លាមៗបន្ទាប់ពីម៉ោងសិក្សា និង

ដោយហេតុថា ក្រុមប្រឹក្សាភិបាលបានផ្តល់ដំណឹងជូនយ៉ាងហោចណាស់ចំនួនដប់ (10) ថ្ងៃ អំពីសវនាការជាសារធារណៈ ដែលបានបិទប្រកាសនៅតាមទីសាធារណៈ យ៉ាងហោចណាស់ ឱ្យបានបីកន្លែងក្នុងសង្កាត់ ដែលក្នុងនោះមានការបញ្ជាក់ពីពេលវេលា ទីកន្លែង និងពីគោលបំណងនៃសវនាការៈ; និង

ដោយហេតុថា ក្រុមប្រឹក្សាភិបាលបានជំរុញឱ្យមានការចូលរួមក្នុងសវនាការជាសាធារណៈពីសំណាក់មាតាបិតា / អាណាព្យាបាល លោកគ្រូ-អ្នកគ្រូ ប្រជាសហគមន៍ និងអ្នកដឹកនាំក្រុមចរចារ; និង

ដោយហេតុថា ព័ត៌មានត្រូវបានផ្តល់ជូនជាលំអិតថែមទៀតនៅក្នុងសវនាការជាសាធារណៈអំពីសៀវភៅសិក្សា និងសម្ភារៈឧបទេសដែលបានផ្តល់ឱ្យកូនសិស្សទាំងអស់ រួមទាំងសិស្សអ្នករៀនអង់គ្លេស ក្នុងសង្កាត់សាលារៀនអូកឡិនដ៍; និង

ដោយហេតុថា និយមន័យនៃ «ការមានសៀវភៅសិក្សា ឬសម្ភារៈឧបទេសគ្រប់គ្រាន់» មានន័យថា សិស្សម្នាក់ៗ រួមទាំងសិស្សអ្នករៀនអង់គ្លេសផងដែរ សុទ្ធតែមានសៀវភៅសិក្សា ឬសម្ភារៈឧបទេស ឬមានទាំងពីរ ដើម្បីប្រើប្រាស់ក្នុងថ្នាក់ និងយកទៅប្រើនៅឯផ្ទះ; និង

ដោយហេតុថា និយមន័យ នៅចន្លោះឆ្នាំសារពើពន្ធ 2008-09 និង 2023-24 នៃ «ការមានសៀវភៅសិក្សា ឬសម្ភារៈឧបទេសគ្រប់គ្រាន់» គឺមានន័យដូចនេះផងដែរ ថាសិស្សទាំងអស់ដែលមានឈ្មោះរៀនក្នុងថ្នាក់តែមួយ នៅក្នុងសង្កាត់សាលារៀនអូកឡិនដ៍ សុទ្ធតែមានសៀវភៅសិក្សា ឬសម្ភារៈឧបទេសតាមស្តង់ដារចេញពីខួបនៃការអនុម័តតែមួយ; និង

ដោយហេតុថា ការមានសៀវភៅសិក្សា និងសម្ភារៈឧបទេសគ្រប់គ្រាន់ ត្រូវបានផ្តល់ឱ្យសិស្សម្នាក់ៗ រួមទាំងសិស្សអ្នករៀនអង់គ្លេសស្រប តាមស្តង់ដារនៃមុខវិជ្ជាសិក្សា ហើយស្របតាមខ្លួប និងអ្វីៗដែលមាននៅក្នុងគំរោងកម្មវិធីសិក្សាក្នុងមុខវិជ្ជាដូចតទៅនេះ៖

គណិតសាស្ត្រ៖

*(នៅឆ្នាំសិក្សា 2021-2022 ការអនុម័តយកសៀវភៅគណិតសាស្ត្រនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសម្រាប់សិស្ស សាលាបឋមសិក្សា, ថ្នាក់ TK និង K-5)។ សម្ភារឧបទេសត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2022-23។*
*នៅឆ្នាំ 2017-18 ការអនុម័តយកសៀវភៅគណិតសាស្ត្រនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសម្រាប់អនុវិទ្យាល័យ, ថ្នាក់ទី 6-8។ សៀវភៅសិក្សាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2018-19។*
*នៅឆ្នាំ 2019-20 ការអនុម័តយកសៀវភៅគណិតសាស្ត្រនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសម្រាប់វិទ្យាល័យ៖ ពិជគណិត 1, ធរណីមាត្រ, ពិជគណិត 2, និងស្ថិតិ AP។ សៀវភៅសិក្សានានាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2020-21។)*

| *កំរិតថ្នាក់* | *មុខវិជ្ជា* | *ក្រុមហ៊ុនបោះពុម្ពសៀវភៅ* |
|---|---|---|
| TK/K | Creative Curriculum Mathematics | Teaching Strategies |
| 1 | Eureka Math Squared | Great Minds |
| 2 | Eureka Math Squared | Great Minds |
| 3 | Eureka Math Squared | Great Minds |
| 4 | Eureka Math Squared | Great Minds |
| 5 | Eureka Math Squared | Great Minds |
| 6 | Illustrative Mathematics | Kendall Hunt |
| 7 | Illustrative Mathematics | Kendall Hunt |
| 8 | Illustrative Mathematics | Kendall Hunt |
| 8 | Illustrative Mathematics Algebra 1 | Kendall Hunt |
| 9 – 12 | Illustrative Mathematics Geometry | Kendall Hunt |
| 9 – 12 | Illustrative Mathematics Algebra 2 | Kendall Hunt |
| 9 – 12 | Probability & Statistics: The Basic Practice of Statistics | Freeman |
| 9 – 12 | AP Statistics: The Practice of Statistics | Freeman |
| 9 – 12 | Precalculus with Trigonometry | Key Curriculum Press |
| 9 – 12 | Calculus-Graphical, Numerical, Algebraic | Pearson-Addison Wesley |

វិទ្យាសាស្ត្រ៖

*(នៅឆ្នាំសិក្សា 2006-2007 ការអនុម័តយកសៀវភៅគណិតសាស្ត្រនៃសង្កាត់សាលារៀនអ្នកឡិនដ៍ ត្រូវបានធ្វើឡើងសម្រាប់កំរិតថ្នាក់ K-12។ សៀវភៅសិក្សាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2007-2008។ មុខវិជ្ជា FOSS Next Generation ត្រូវបានអនុម័តយក និងសម្ភារៈត្រូវបានជាវសម្រាប់សាលាបឋមសិក្សានៅឆ្នាំសិក្សា 2018-19 និងអនុវិទ្យាល័យនៅឆ្នាំសិក្សា 2019-20)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| TK | Foss Next Generation: Observing Nature | Foss/Delta Education |
| K | FOSS Next Generation: Materials and Motion, Trees and Weather, Animals Two by Two | Foss/Delta Education |
| 1 | FOSS Next Generation: Sound and Light; Air and Weather; Plants and Animals | Foss/Delta Education |
| 2 | FOSS Next Generation: Solids and Liquids; Pebbles, Sand, and Silt; Insects and Plants | Foss/Delta Education |
| 3 | FOSS Next Generation: Motion and Matter; Water and Climate; Structures of Life | Foss/Delta Education |
| 4 | FOSS Next Generation: Energy; Soils, Rocks and Landforms; Environments | Foss/Delta Education |
| 5 | FOSS Next Generation: Mixtures and Solutions; Earth and Sun; Living Systems | Foss/Delta Education |
| 6 | FOSS Next Generation: Weather & Water; Diversity of Life; Human Systems Interactions | Foss/Delta Education |
| 7 | FOSS Next Generation: Chemical Interactions; Earth History; Populations and Ecosystems | Foss/Delta Education |
| 8 | FOSS Next Generation: Heredity and Adaptation, Electromagnetic Force; Gravity and Kinetic Energy; Waves; Planetary Science | Foss/Delta Education |
| 9 – 12 | Biology: Biology by Nowicki (lab class) | McDougall Littell |
| 9 – 12 | Biology AP: Biology by Campbell (lab class) | Pearson |
| 9 – 12 | Chemistry (lab class) | Pearson |
| 9 – 12 | Chemistry AP: Chemistry the Central Science (lab class) | Pearson |
| 9 – 12 | Physics: Conceptual Physics by Hewitt (lab class) | Pearson |
| 9 – 12 | Physics AP: Physics by Cutnell & Johnson (lab class) | People Press |
| 9 – 12 | Physiology: Essentials of Anatomy & Physiology (lab class) | Pearson |
| 9 – 12 | Environmental Science: A Study of Interrelationships | McGraw Hill |
| 9 – 12 | Environmental Science AP: Living in the Environment (lab) | Thompson |
| 9 – 12 | Geology: Earth Science, 11th Edition | Pearson |

## គ្រឿងបរិក្ខាសម្រាប់ថ្នាក់វិទ្យាសាស្ត្រពិសោធ

*ថ្នាក់ទី 9 -12*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| 9 – 12 | Science Lab: Bunson Burner | N/A |
| 9 – 12 | Science Lab: Dissecting Kit | N/A |
| 9 – 12 | Science Lab: Goggles | N/A |
| 9 – 12 | Science Lab: Hot Plate | N/A |
| 9 – 12 | Science Lab: Microscope | N/A |
| 9 – 12 | Science Lab: Slides & Cover Slips | N/A |
| 9 – 12 | Science Lab: Scale Triple Beam or Digital | N/A |
| 9 – 12 | Science Lab: Graduated Cylinder 1 Liter | N/A |
| 9 – 12 | Science Lab: Graduated Cylinder 5 ml | N/A |
| 9 – 12 | Science Lab: Graduated Cylinder 10 ml | N/A |
| 9 – 12 | Science Lab: Graduated Cylinder 100 ml | N/A |
| 9 – 12 | Science Lab: Flasks | N/A |
| 9 – 12 | Science Lab: Beakers 10ml | N/A |
| 9 – 12 | Science Lab: Beakers 100 ml | N/A |
| 9 – 12 | Science Lab: Beakers 250 ml | N/A |
| 9 – 12 | Science Lab: Beakers 500 ml | N/A |
| 9 – 12 | Science Lab: Test Tubes Small | N/A |
| 9 – 12 | Science Lab: Test Tubes Large | N/A |
| 9 – 12 | Science Lab: Pipettes | N/A |

ប្រវត្តសាស្ត្រ-សង្គមវិទ្យា៖

*(នៅឆ្នាំសិក្សា 2005-2006 ការអនុម័តយកសៀវភៅសង្គមវិទ្យានៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសម្រាប់កំរិតថ្នាក់ទី 4-12 ។ សៀវភៅសិក្សាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2006-2007។*
*នៅឆ្នាំសិក្សា 2006-2007 ការអនុម័តយកសៀវភៅសង្គមវិទ្យានៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានធ្វើឡើងសម្រាប់កំរិតថ្នាក់ K-3។ សៀវភៅសិក្សា ត្រូវបានជាវទុកសម្រាប់ឆ្នាំសិក្សា 2007-2008។ កម្មវិធីសិក្សាថ្នាក់ទី 6-8 ត្រូវបានអនុម័ត និងជាវក្នុងឆ្នាំ 2018-19។ កម្មវិធីសិក្សាថ្មីសម្រាប់ថ្នាក់ទី 4-5 ត្រូវបានអនុម័តសម្រាប់ឆ្នាំសិក្សា 2021-22។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| TK | Creative Curriculum | Teaching Strategies |
| K | Our World, Now & Long Ago Big Book | Harcourt |
| K | Our World, Now & Long Ago Big Book, Spanish | Harcourt |
| 1 | A Child's View Big Book, Units 1-6 | Harcourt |
| 1 | A Child's View Big Book, Units 1-6 Spanish | Harcourt |
| 2 | People We Know | Harcourt |
| 2 | People We Know, Spanish | Harcourt |
| 3 | Our Communities | Harcourt |
| 3 | Our Communities, Spanish | Harcourt |
| 4 | Oakland 4th Grade Social Studies Curriculum | Newsela |
| 5 | Oakland 5th Grade Social Studies Curriculum | Newsela |
| 6 | Ancient Civilizations: myWorld Interactive | Pearson |
| 7 | Medieval and Early Modern Times: myWorld Interactive | Pearson |
| 8 | Growth and Conflict: myWorld Interactive | Pearson |
| 9 – 12 | World History: The Modern World c.2007 | Pearson |
| 9 – 12 | World History AP: Traditions & Encounters c.2006 | McGraw Hill |
| 9 – 12 | US History: American Anthem | Holt, Reinhart, Wilson |
| 9 – 12 | US History AP: American Past & Present 7th Edition | Holt, Reinhart, Wilson |
| 9 – 12 | Magruder's American Government | Pearson |
| 9 – 12 | American Government AP: Continuity & Change | Pearson |
| 9 – 12 | Contemporary Economics | Thompson |

## សិល្បៈភាសាអង់គ្លេស / សិល្បៈភាសាអេស្ប៉ាញ៖

*(នៅឆ្នាំសិក្សា 2022-23 សង្កាត់សាលារៀនអូកឡិនដ៍បានអនុម័តយកសៀវភៅ ELA សម្រាប់ថ្នាក់ 9។ សម្ភារៈឧបទេសត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2023-24។ នៅឆ្នាំសិក្សា 2020-2021 សង្កាត់សាលារៀនអូកឡិនដ៍បានអនុម័តយកសៀវភៅ ELA និង SLA សម្រាប់ថ្នាក់ K-5។ សម្ភារៈឧបទេសត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2021-22។  នៅឆ្នាំសិក្សា 2015-2016 សង្កាត់សាលារៀនអូកឡិនដ៍បានអនុម័តយកសៀវភៅ ELA សម្រាប់ថ្នាក់ 6-8។ សម្ភារៈឧបទេសត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2016-2017។ នៅឆ្នាំសិក្សា 2003-2004 សង្កាត់សាលារៀនអូកឡិនដ៍បានអនុម័តយកសៀវភៅ ELA សម្រាប់កំរិតថ្នាក់ 9-12។ សៀវភៅសិក្សាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2004-2005។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| TK | Creative Curriculum | Teaching Strategies |
| Kinder | EL Education Student Books and text sets for 4 modules: Toys and Play, Weather Wonders, Trees are Alive, Enjoying and Appreciating Trees | EL Education<br>Booksource |
| Kinder | Dual Language Immersion: Adelante (Spanish) and Advance (English) student books and text sets for 10 units | Benchmark |
| 1 | EL Education Student Books and text sets for 4 modules: Tools and Work; Sun, Moon and Stars; Birds' Amazing Bodies; Caring for Birds | EL Education<br>Booksource |
| 1 | Dual Language Immersion: Adelante (Spanish) and Advance (English) student books and text sets for 10 units | Benchmark |
| 2 | EL Education Student Books and text sets for 4 modules: Schools and Community; Fossils tell of Earth's Changes; The Secret World of Pollinations; Providing for Pollinators | EL Education<br>Booksource |
| 2 | Dual Language Immersion: Adelante (Spanish) and Advance (English) student books and text sets for 10 units | Benchmark |
| 3 | EL Education Student Books and text sets for 4 modules: Overcoming Learning Challenges Near and Far; Adaptations and the Wide World of Frogs; Exploring Literary Classics; Water Around the World | EL Education<br>Booksource |
| 3 | Dual Language Immersion: Adelante (Spanish) and Advance (English) student books and text sets for 10 units (Dual Language Immersion) | Benchmark |
| 4 | EL Education Student Books and text sets for 4 modules: Poetry, Poets and Becoming Writers; Animal Defense Mechanisms, The American Revolution; Responding the Inequality; Ratifying the 19th Amendment | EL Education<br>Booksource |
| 4 | Dual Language Immersion: Adelante (Spanish) and Advance (English) student books and text sets for 10 units | Benchmark |
| 5 | EL Education Student Books and text sets for 4 modules: Stories of Human Rights; Biodiversity in the Rain Forest; Athlete Leaders of Social Change; The Impact of Natural Disasters | EL Education<br>Booksource |
| 5 | Dual Language Immersion: Adelante (Spanish) and Advance (English) student books and text sets for 10 units | Benchmark |
| 6 | EL Education Student texts for 3 modules: Greek Mythology; Remarkable Accomplishments in Space Science; and American Indian Boarding Schools or Critical Problems and Design Solutions | EL Education<br>Booksource |
| 7 | EL Education Student texts for 3 modules: The Lost Children of Sudan; Epidemics; and Harlem Renaissance or Plastic Pollution | EL Education<br>Booksource |
| 8 | EL Education Student texts for 3 modules: Folklore of Latin America, Lessons from Japanese-American Internment; and Food Choices or | EL Education |

| | | |
|---|---|---|
| | Voices of the Holocaust | Booksource |
| 6-8 | English 3D | HMH |
| 6-8 | National Geographic Inside the USA | Cengage |
| 6-8 | National Geographic Fundamentals | Cengage |
| 9 | Fishtank Texts for 3 modules: Unit 1: Me, Myself, and I Examining Personal Identity in Short texts, Unit 2: Born A Crime, Unit 3: Time of the Butterflies | Holt |
| 10 | Literature & Language Arts: 4th Course | Holt |
| 10 | *Purple Hibiscus*, *Things Fall Apart* | Novels |
| 10 | Springboard Level 5 | CollegeBoard |
| 11 | Literature & Language Arts: 5th Course | Holt |
| 11 | *Huckleberry Finn*, *Fences*, *Their Eye's are Watching God* | Novels |
| 11 | Springboard Level 6 | CollegeBoard |
| 12 | Literature & Language Arts: 6th Course | Holt |
| 12 | Springboard Senior English | CollegeBoard |
| 9-12 | English 3 AP: Norton Reader | Peoples Press |
| 9-12 | English 4 AP: Bedford's Anthology | VHPS |
| 9-12 | English 4 AP: Perrine's Sound & Sense | Thompson |

ថ្នាក់អភិវឌ្ឍភាសាអង់គ្លេស / ថ្នាក់សម្រាប់សិស្សចំណូលថ្មី ឬសិស្សអ្នករៀនភាសាអង់គ្លេសសម្រាប់រយៈពេលយូរ

| *កំរិតថ្នាក់* | *មុខវិជ្ជា* | *ក្រុមហ៊ុនបោះពុម្ពសៀវភៅ* |
|---|---|---|
| 6 – 8 | ELD 5/LTEL: English 3D | HMH |
| 6 – 8 | ELD 1: National Geographic Inside the USA | Cengage |
| 6 – 8 | ELD 1-5: National Geographic Edge | Cengage |
| 6 – 8 | ELD 1-5: Holt Literature and Language Arts | Holt |
| 9 – 12 | ELD 5/LTEL: English 3D | HMH |
| 9 – 12 | ELD 1: National Geographic Inside the USA | Cengage |
| 9 – 12 | ELD 1-5: National Geographic Edge | Cengage |
| 9 – 12 | ELD 1-5: Holt Literature and Language Arts | Holt |

ភាសាពិភពលោក៖

*(នៅឆ្នាំសិក្សា 2015-2016 សង្កាត់សាលារៀនអូកឡិនដ៍បានអនុម័តយកសៀវភៅភាសាពិភពលោកសម្រាប់កំរិតថ្នាក់ 6-12។ សៀវភៅសិក្សាត្រូវបានជាវសម្រាប់ឆ្នាំសិក្សា 2016-2017។)*

| កំរិតថ្នាក់ | មុខវិជ្ជា | ក្រុមហ៊ុនបោះពុម្ពសៀវភៅ |
|---|---|---|
| 6 – 8 | Spanish A/B: Adelante A/B | Holt |
| 6 – 8 | Spanish I: En Espanol | McDougall Littell |
| 6 – 8 | French A/B: Bon Voyage | Glencoe |
| 6 – 8 | French I: Discovering French Bleu | McDougall Littell |
| 9 – 12 | Spanish I: Que Chevere | EMC |
| 9 – 12 | Spanish II: Que Chevere | EMC |
| 9 – 12 | Spanish III: Que Chevere | EMC |
| 9 – 12 | Spanish IV: Que Chevere | EMC |
| 9 – 12 | EPH II: Imagina | Vista Higher Learning |
| 9 – 12 | EPH III: Imagina | Vista Higher Learning |
| 9 – 12 | EPH IV: Abriendo Paso Lecture | Prentice Hall |
| 9 – 12 | EPH IV: Abriendo Paso Grammatica | Prentice Hall |
| 9 – 12 | EPH V: Abriendo Puertas Vol.1 | McDougall Littell |
| 9 – 12 | EPH V: Abriendo Puertas Vol.2 | McDougall Littell |
| 9 – 12 | French I: T’es Branche | EMC |
| 9 – 12 | French II: T’es Branche | EMC |
| 9 – 12 | French III: T’es Brance | EMC |
| 9 – 12 | French IV: Tresors du Temps | Glencoe |
| 9 – 12 | AP French: Themes | Vista Higher Learning |
| 9 – 12 | AP French: Themes | Vista Higher Learning |
| 9 – 12 | AP Spanish Literature: Reflexiones | Pearson |
| 9 – 12 | AP Spanish Language: Temas | Vista Higher Learning |
| 9 – 12 | Mandarin I-III: Zhen Bang Levels 1-3 | EMC |

ដូច្នេះឥឡូវនេះ នឹងត្រូវបានដោះ ថាក្រុមប្រឹក្សាគ្រប់គ្រងនៃសង្កាត់ តាមរយៈនេះ សូមប្រកាស់ សូមស្វែងរក និងអនុម័តរបាយការណ៍ នៅទីនេះ ដោយថ្លែងថាសង្កាត់ សម្រាប់ឆ្នាំសិក្សា 2023-24 សង្កាត់បានផ្តល់ឱ្យសិស្សម្នាក់ៗ នូវសៀវភៅសិក្សា និងសម្ភារៈឧបទេសគ្រប់គ្រាន់ដែលស្របតាមស្តង់ដារមាតិកាសិក្សា និងស្របតាមខ្ទប និងអ្វីៗដែលមាននៅក្នុងគ្រោងក្របខ័ណ្ឌនៃកម្មវិធីសិក្សា។

បានបោះឆ្នោតអនុម័ត និងទទួលយក នៅ<u>ថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2023</u> នេះ នៅក្នុងកិច្ចប្រជុំធម្មតាមួយរបស់ក្រុមប្រឹក្សាភិបាល តាមការបោះឆ្នោតដូចតទៅនេះ៖

បោះឆ្នោតគាំទ្រ៖

បោះឆ្នោតបដិសេធ៖

បោះឆ្នោតអនុបវាទ៖

អវត្តមាន៖

ខ្ញុំបាទ/នាងខ្ញុំ តាមរយៈនេះ សូមបញ្ជាក់ថា អ្វីៗដែលបានជំរាបជូននៅខាងលើនេះ គឺជាដំណោះស្រាយពេញលេញ ពិតប្រាកដ និងត្រឹមត្រូវ ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំធម្មតានៃក្រុមប្រឹក្សាភិបាលនៃសង្កាត់សាលារៀនអូកឡិនដ៍ ដែលបានធ្វើនៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2023៕

ធ្វើនៅ<u>ថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2023</u>

________________________________

Kyla Johnson-Trammell
លេខាធិការ, ក្រុមប្រឹក្សាភិបាល
សង្កាត់សាលារៀនអូកឡិនដ៍